مدرسة اهل البيت

# សាលា
# អាស់លុល-បៃត៍

## សៀវភៅ ហ្វីកោះហ្វ៍ ថ្នាក់ទី ២ (អាយុ ៦-៧ ឆ្នាំ)

រ៉ស៊ូលុលឡោះហ៊្ស ﷺ មានព្រះវចនៈថាៈ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - អល់ឡោះហ្ម៍ (الله)......................................................................៣
មេរៀនទី ២ - ខ្ញុំមិនអាចមើលឃើញអល់ឡោះហ្ម៍ទេ ............................................ ៦
មេរៀនទី ៣ - ក៏្ញឌីម (قَدِيم) ....................................................................១០
មេរៀនទី ៤ - ក៏្ញឌីរ (القادر)......................................................................១៣
មេរៀនទី ៥ - អ៊ាលីម (العليم)......................................................................១៥
មេរៀនទី ៦ - ហៃ្ញ (الحي)..........................................................................១៨
មេរៀនទី ៧ - មូរីដ្ឋ (المريد) ...................................................................... ២១
មេរៀនទី ៨ - មុដ្ឋរិក (المودريك) ................................................................ ២៤
មេរៀនទី ៩ - មូតាកាល់លិម (المتكلم)...............................................................២៧
មេរៀនទី ១០ - ស៏្ញឌិក្ញ (الصادق)................................................................៣០
មេរៀនទី ១១ - កាយវិការស៏្ញឡាត្ញុំ ............................................................... ៣៣
មេរៀនទី ១២ - រ្ញួឌុអ៊ុ - អធិប្បាយ ................................................................៣៨
មេរៀនទី ១៣ - រ្ញួឌុអ៊ុ - ទង្វើសូ្ញណាត្ញុំ ........................................................៤១
មេរៀនទី ១៤ - រ្ញួឌុអ៊ុ - ទង្វើវ៉ាយិ្ញប ៖ លាងមុខ ..............................................៤៤
មេរៀនទី ១៥ - រ្ញួឌុអ៊ុ - ទង្វើវ៉ាយិ្ញប ៖ លាងដៃ ...............................................៤៧
មេរៀនទី ១៦ - រ្ញួឌុអ៊ុ - ទង្វើវ៉ាយិ្ញប ៖ ម៉ាសាស៊្ញុ ..............................................៤៩
មេរៀនទី ១៧ - រ្ញួឌុអ៊ុសរុប (សាឡើងវិញ) .........................................................៥១
មេរៀនទី ១៨ - រ្ញួឌុអ៊ុសរុប (អនុវត្តន៍បង្ហាញ)....................................................៥៥
មេរៀនទី ១៩ - តាស់បិ៊ះហ៊្ញ ..........................................................................៥៦

**មេរៀនទី ១**

# អល់ឡោះហ៍ (ﷲ)

មានតែព្រះមួយគត់ ព្រះនាមរបស់ព្រះអង្គគឺ **អល់ឡោះហ៍** (ﷲ) ។

អល់ឡោះហ៍ជាអ្នកណា ?

- ព្រះអង្គបានបង្កើតយើងទាំងអស់គ្នា និងបានបង្កើតសព្វគ្រប់ដែលមាននៅជុំវិញយើង ។
- ព្រះអង្គគឺព្រះដែលការពារយើង ។
- ព្រះអង្គគឺព្រះដែលយើងសូមជំនួយ ។
- ព្រះអង្គព្រះដែលយើងស្ដាប់បង្គាប់ ។
- ព្រះអង្គគឺព្រះដែលយើងនឹងវិលទៅរកវិញ ។

ព្រោះតែអអល់ឡោះហ៍បានធ្វើអ្វីៗសម្រាប់យើង និងបានព្រះរាជទានយ៉ាងច្រើនឲ្យយើង យើងត្រូវតែនឹកឃើញព្រះអង្គមុននឹងចាប់ផ្ដើមធ្វើមួយដោយថា៖

بِسْـــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

*(ខ្ញុំចាប់ផ្ដើម) ដោយព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

កាលណាយើងថាពាក្យនេះ អល់ឡោះហ៍ជួយយើង ព្រះអង្គធ្វើឲ្យស្ហៃតនឃ្លាតឆ្ងាយពីយើង ព្រោះវាអាចមកបំផ្លិចបំផ្លាញអ្វីដែលយើងកំពុងធ្វើ ។

ក្នុងសម័យថ្ងៃមួយ បុរសម្នាក់បានមកដល់សាលារៀនយឺតពេលរាល់ដង ។ ថ្ងៃមួយគ្រូរបស់គាត់បានសួរគាត់ ថាហេតុអ្វីគាត់មកដល់សាលារៀនយឺតពេលរាល់ដង ។ គាត់បានប្រាប់ថាគាត់ត្រូវជិះទូកឆ្លងស្ទឹងដើម្បីទៅកាន់សាលារៀន ហើយទូកនេះ

មកយឺតពេលរាល់ដង ។

គ្រូគាត់បានប្រាប់គាត់ ថាលោកនឹងឲ្យគាត់នូវសន្លឹកក្រដាសមួយដែលមានសំណេរអក្សរពិសេស ។ អាស្រ័យក្រដាសមួយសន្លឹកនេះនៅក្នុងដៃ បុរសនេះអាចដើរលើទឹកបាន ក៏ប៉ុន្តែហាមផ្តាច់មិនឲ្យគាត់មើលអ្វីដែលសរសេរនៅលើសន្លឹកក្រដាសនោះទេ ។

ស្អែកឡើង បុរសនោះបានមកដល់មាត់ស្ទឹងជាមួយសន្លឹកក្រដាសនៅក្នុងដៃ គាត់បានឈានជើងទៅលើផ្ទៃទឹកហើយក៏បានដើរលើទឹក ។ បុរសរូបនេះបានមកដល់សាលារៀនទាន់ពេលវេលា ។

រៀងរាល់ព្រឹក បុរសនោះបានដើរលើទឹក ហើយបានមកដល់សាលារៀនទាន់ពេលវេលា លុះថ្ងៃមួយគាត់បានបើកមើលអ្វីដែលគ្រូគាត់បានសរសេរនៅលើសន្លឹកក្រដាសនោះ ។ មានសរសេរថា៖ بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

បុរសនេះនឹកក្នុងចិត្តថា៖ "មានសរសេរតែប៉ុណ្ណេះឯង ។" បន្ទាប់ពីនោះ គាត់បានកាន់ក្រដាសនោះទៅដើរលើទឹក តែគ្រានេះគាត់លិចទៅក្នុងទឹក ។ គាត់បានសាកល្បងច្រើនលើកច្រើនគ្រាតែពុំអាចដើរលើទឹកបានទៀតទេ ។

ថ្ងៃនោះ គាត់មកដល់សាលាយឺតពេលទៀតព្រោះគាត់ត្រូវជិះទូកឆ្លងស្ទឹង ។ ពេលគ្រូគាត់បានឃើញគាត់មកយឺតពេល លោកបានប្រាប់គាត់ថានេះព្រោះតែគាត់គិតថាអ្វីដែលសរសេរនៅលើសន្លឹកក្រដាសនោះមិនសំខាន់ណាស់ទេ ។ គាត់ពុំអាចដើរលើទឹកបានទៀតទេ ។

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ មានឥទ្ធិពលខ្លាំងណាស់ បើអ្នកទាំងអស់គ្នាជឿពិតប្រាកដលើពាក្យមួយឃ្លានេះ ។

**កិច្ចការសិស្ស ១**

بِسْــمِ اللهِ الرَّحْمٰنِ الرَّحِيْمِ

*(ខ្ញុំចាប់ផ្តើម) ដោយព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*



ចូរគូរបីគំនូរដោយចាប់ផ្តើមដោយសូត្រ៖ بِسْــمِ اللهِ الرَّحْمٰنِ الرَّحِيْمِ

**មេរៀនទី ២**

# ខ្ញុំមិនអាចមើលឃើញអល់ឡោះហ្វទេ

ថ្ងៃមួយត្វ័លិបបានសួរម្តាយវាថាៈ "ហេតុអ្វីខ្ញុំមិនអាចមើលឃើញអល់ឡោះហ្វ ?"

ម្តាយត្វ័លិបបានឆ្លើយថាៈ "អល់ឡោះហ្វមិនមែនវត្ថុដែលគេអាចមើលឃើញទេ ។ ពុំដែលមានអ្នកណាធ្លាប់ឃើញព្រះអង្គទេ ហើយនឹងពុំមានអ្នកណាមើលឃើញព្រះអង្គឡើយ ។"

ត្វ័លិបថាៈ "ម៉ែ បើយើងមិនអាចមើលឃើញអល់ឡោះហ្វទេ តើគេនឹងដឹងច្បាស់ម្តេចទៅ ?"

ម្តាយត្វ័លិបញញឹម ហើយបានប្រាប់ត្វ័លិបឲ្យក្តិចខ្លួនឯង ។

ត្វ័លិបជាក្មេងមុស្លីមល្អម្នាក់ បានក្តិចខ្លួនឯងយ៉ាងខ្លាំងដោយមិនតវ៉ា ។

ត្វ័លិបថាៈ "អូយ ! ឈឺ !"

ម្តាយត្វ័លិបបានរាវរកកន្លែងដែលត្វ័លិបបានក្តិចខ្លួនឯង ហាក់ដូចជាគាត់រាវរកអ្វីម្យ៉ាង ។

ត្វ័លិបថាៈ "ម៉ែរកអ្វី ?"

ម្តាយត្វ័លិបថាៈ "ម៉ែរកសេចក្តីឈឺចាប់ ។"

ត្វ័លិបមើលមុខម្តាយដោយសេចក្តីភ្ញាក់ផ្អើលថាៈ "ម៉ែ គេមើលសេចក្តីឈឺចាប់មិន

ឃើញទេ ។" ម្ដាយត្រ៏លិបញញឹម ហើយថា៖ "ដូចសេចក្ដីឈឺចាប់នេះដែរដែលនៅត្រង់នេះតែមើលមិនឃើញនោះ អល់ឡោះហ្វ៍ក៏នៅនេះដែរដែលគេមើលមិនឃើញ ។"

បន្ទាប់មក គាត់និយាយបន្តថា៖ "ទោះបីកូនឯងមិនអាចមើលឃើញអល់ឡោះហ្វ៍ក៏ដោយ កូនឯងអាចមើលឃើញអ្វីៗដែលព្រះអង្គបានបង្កើតមកដោយមើលខ្លួនឯងនិងមើលជុំវិញខ្លួនឯង ។"







ព្រះសាស្ដាយើងមានព្រះវចនៈថា៖ "ពេលអស់លោកបានឃើញដានជើងអូដ្ឋនៅលើខ្សាច់ អស់លោកសន្និដ្ឋានថាអូដ្ឋបានដើរកាត់តាមនេះ ទោះបីអស់លោកមិនបានឃើញអូដ្ឋនោះក៏ដោយ ។"

ដូចគ្នាដែរ ពេលអ្នកទាំងអស់គ្នាឃើញអ្វីៗសព្វគ្រប់ដែលអល់ឡោះហ្វ៍បានបង្កើតមក

អ្នកទាំងអស់គ្នាមានអារម្មណ៍ថាព្រះអង្គមានវត្តមាននៅនេះ ទោះបីគេមើលមិនឃើញព្រះអង្គក៏ដោយ ។

## កិច្ចការសិស្ស ២

ចូរសាកល្បងមើលសេចក្ដីឈឺចាប់ពេលអ្នកក្ដិចខ្លួនឯង ទោះបីអ្នកមើលមិនឃើញសេចក្ដីឈឺចាប់នោះក៏ដោយ អ្នកដឹងច្បាស់ថាវាមានវត្តមាននៅនេះមែនទេ ?

ចូរផាត់ព័ណ៌នៅលើគំនូរខាងក្រោមនេះ ។ រួចហើយចូរយកដៃបាំងរូបអូដ្ឋនេះឲ្យជិត ។ ពេលឃើញដានជើង អ្នកដឹងថាសត្វអូដ្ឋបានមានវត្តមាននៅទីនេះ ទោះបីពេលនេះអ្នកមិនឃើញវាក៏ដោយ ។



ទាំងនេះគឺអ្វីដែលអស់ឡោះហ្វ៍បង្កើតមក ដែលអ្នកដឹងថាវាមានវត្តមានតែមើលមិនឃើញទេ ។





**មេរៀនទី ៣**

# ក្ហ៏ឌីម (قَدِيم)

អល់ឡោះហ្ទ៍ជា **ក្ហ៏ឌីម** - ព្រះអង្គពុំមានដើមទីនិងពុំមានទីបញ្ចប់ទេ ។

អល់ឡោះហ្ទ៍មិនបានចាប់កំណើត ព្រះអង្គនឹងមិនស្លាប់ឡើយ ។

អល់ឡោះហ្ទ៍ទ្រង់ធ្លាប់តែមានព្រះវត្តមាន ព្រះអង្គនឹងមានព្រះវត្តមានតរៀងទៅជានិច្ច ។

អល់ឡោះហ្ទ៍បានបង្កើតមកនូវអ្វីៗសព្វគ្រប់ តែពុំមានអ្នកណាបានបង្កើតព្រះអង្គមកទេ ព្រោះព្រះអង្គតែងតែមានព្រះវត្តមានជានិច្ច ។

អល់ឡោះហ្ទ៍ឃាមនិងការពារសត្វលោកទាំងអស់និងអ្វីៗទាំងអស់ ព្រះអង្គត្រូវតែមានព្រះវត្តមាន ព្រះអង្គមិនអាចស្លាប់ឡើយ ឬមិនអាចចាកចេញឡើយ ។

ត៏ូលិបមិនយល់ទេថា អល់ឡោះហ្ទ៍ពុំមានដើមទីនិងពុំមានទីបញ្ចប់ទេ នោះគឺអ្វីទេ ។

ម្តាយត៏ូលិបបានពន្យល់ត៏ូលិបថា កាលពីមុនត៏ូលិបមិនទាន់មានវត្តមាននៅឡើយទេ (ពោល គឺ មិនទាន់កើតនៅឡើយទេ) ក្រោយមក ត៏ូលិបបានចាប់កំណើត ហើយនេះឯងជាដើមទី (គឺការចាប់ផ្តើមដំបូង) របស់ត៏ូលិប ។ ត៏ូលិបបានធំឡើងនឹងទៅជាមនុស្សពេញវ័យ ហើយនឹងទៅជាមនុស្សចាស់ បន្ទាប់មកនឹងស្លាប់ហើយត្រឡប់ទៅឯអល់ឡោះហ្ទ៍វិញ នេះហើយគឺទីបញ្ចប់របស់ត៏ូលិប ។

ចាប់ពីត្រឹមនេះទៅ ម្តាយត៏ូលិបបានពន្យល់ត៏ូលិបថា អល់ឡោះហ្ទ៍មិនមានដើមទីទេនោះ ពីព្រោះពុំមានពេលណាមួយដែលអល់ឡោះហ្ទ៍មិនមានព្រះវត្តមាន (មិនគង់

នៅ) នោះទេ ព្រះអង្គរមែងតែគង់នៅ (មានព្រះវត្តមាន) ជានិច្ចមិនខកខាន ។ ហើយព្រះអង្គមិនមានទីបញ្ចប់ទេ  នោះពីព្រោះនឹងមិនមានពេលណាមួយដែលព្រះអង្គនឹងមិនគង់នៅនោះឡើយ ។

ដូច្នេះ អល់ឡោះហ្វ៍ជាក្ទ័ឌ្ទីម ព្រះអង្គមិនមានដើមទីនិងមិនមានអវសានទេ ។

# កិច្ចការសិស្ស ៣

អល់ឡោះហ្វ៍ជាក្ស៊ីម ព្រះអង្គមិនមានដើមទីនិងមិនមានអវសានទេ ។



ស៊ុតទា



កូនទា



ទា

**អល់ឡោះហ្វ៍** **អល់ឡោះហ្វ៍** **អល់ឡោះហ្វ៍**

ខ្ញុំកាលនៅជាទារក ខ្ញុំនៅពេលនេះ ខ្ញុំក្នុងវ័យចំណាស់

ចូរបិទ នៅក្នុងប្រឡោះបួនជ្រុងខាងលើនេះ រូបថតអ្នកកាលអ្នកជាទារក រូបថតអ្នកនៅបច្ចុប្បន្ន និងរូបថតម្តាយអ្នកឬឪពុកអ្នក ពីព្រោះអ្នកនឹងដូចលោកឪពុកអ្នកម្តាយអ្នកដែរនៅពេលខាងមុខ ។

**មេរៀនទី ៤**

# ក៏ឌៀរ (القادر)

អល់ឡោះហ្វ៍ជា **ក៏ឌៀរ** - ព្រះអង្គមានព្រះមហិទ្ធិឫទ្ធិ និងខ្លាំងពូកែបំផុត ។

អល់ឡោះហ្វ៍បានបង្កើតអ្វីៗគ្រប់សព្វ ព្រះអង្គមានអំណាចលើអ្វីៗគ្រប់សព្វនិងលើសត្វលោកទាំងអស់ ។

ពុំមានអ្នកណានិងពុំមានអ្វីខ្លាំងពូកែជាងព្រះអង្គឡើយ ។ ព្រះអង្គខ្លាំងពូកែបំផុត ។

ដូច្នេះហើយបានជាយើងត្រូវសូមជំនួយពីព្រះអង្គតែមួយគត់ ព្រោះការពិតមានតែព្រះអង្គមួយទេដែលអាចជួយយើងបាន ។

យប់មួយ ត៊ូលិបបានភ្ញាក់ពីដំណេកដោយភ័យរន្ធត់ ។ ពេលម្តាយត៊ូលិបបានសួរថាមានអ្វីកើតឡើង ត៊ូលិបបានឆ្លើយថាវាបានយល់សប្តិអាក្រក់ឃើញខ្មោច ។

ត៊ូលិបចង់យកប្រដាប់លេងស៊ុបភើមេនមកដេកជាមួយពីព្រោះ បើខ្មោចមកម្តងទៀតស៊ុមភើមេននឹងប្រយុទ្ធតទល់នឹងខ្មោច ព្រោះស៊ុបភើមេនខ្លាំងពូកែ ។

ម្តាយត៊ូលិបបានប្រាប់ត៊ូលិបថា យកល្អឲ្យត៊ូលិបសូមជំនួយពីអល់ឡោះហ្វ៍វិញព្រោះព្រះអង្គខ្លាំងពូកែបំផុតហើយជាព្រះពិតប្រាកដ ឯស៊ុបភើមេននោះវិញមិនពិតទេ ។

បន្ទាប់មក គាត់បាននិយាយទៀតថាទោះបីស៊ុបភើមេនពិតក៏ដោយ ក៏នៅតែមិនខ្លាំងពូកែជាងអល់ឡោះហ្វ៍ទេ ព្រោះអល់ឡោះហ្វ៍បានប្រទានកម្លាំងឲ្យយើងរាល់គ្នា ។

អល់ឡោះហ្វ៍ជាក៏ឌៀរ ព្រះអង្គខ្លាំងពូកែបំផុត ព្រះអង្គមានព្រះមហិទ្ធិឫទ្ធិបំផុត ។

## កិច្ចការសិស្ស ៤

អល់ឡោះហ្វ៍ជាក្ប៏ខ្បៀរ ព្រះអង្គមានព្រះមហិទ្ធិឫទ្ធិបំផុត ព្រះអង្គខ្លាំងពូកែបំផុត ។












**មេរៀនទី ៥**

# អាុលីម (العليم)

អល់ឡោះហ្វ៍ជា **អាុលីម** - ព្រះអង្គទ្រង់ញាណអ្វីៗសព្វគ្រប់ ។

ពុំមានអ្វីលាក់បាំងពីអល់ឡោះហ្វ៍ឡើយ ។

ព្រះអង្គទ្រង់ញាណអ្វីដែលអ្នកស្រែកពួៗ ព្រះអង្គទ្រង់ញាណអ្វីដែលអ្នកខ្សឹប ទោះបី អ្នកគិតក្នុងចិត្ត មិននិយាយខ្លាំងៗ ក៏ព្រះអង្គទ្រង់ញាណដែរ ។

ព្រះអង្គទ្រង់ញាណថាអ្នកជាមនុស្សល្អ ឬជាមនុស្សអាក្រក់ ។

ព្រះអង្គទ្រង់ញាណថាអ្នកនិយាយពិត ឬនិយាយកុហក ។

ព្រះអង្គទ្រង់ញាណពេលអ្នកសប្បាយចិត្ត និងពេលអ្នកមានបារម្ភ ។

ព្រះអង្គទ្រង់ញាណពេលអ្នកត្រូវការជំនួយ ហើយព្រះអង្គទ្រង់ជួយអ្នក ។

ព្រះអង្គទ្រង់ញាណសព្វសារពើ ។

ម្តាយត៍្តលិបចង់ដឹងថា តើត៍្តលិបប្រាកដជាយល់ឬទេថា អល់ឡោះហ្វ៍ជាអាុលីម ។ ថ្ងៃមួយ ពេលត៍្តលិបបានត្រឡប់មកពីសាលារៀនវិញ ម្តាយត៍្តលិបបានឲ្យអំណោយត៍្តលិបមួយ ហើយបានថា៖ "កូនឯងត្រូវបើកមើលអំណោយនេះនៅកន្លែងណាដែលមិនមានអ្នកណាឃើញកូនឯង ។"

ត៍្តលិបគិតថាវាជាការងាយស្រួលណាស់ ។ ត៍្តលិបបានយកកញ្ចប់អំណោយឡើង

ទៅលើផ្ទះតែឪពុកវានៅទីនោះ ។ ត៊្លិបទៅឯក្នុងសួនតែមានចាបនៅទីនោះ ។ បន្ទាប់មក ត៊្លិបបានទៅក្នុងបន្ទប់ទឹកតែមានពីងពាងតូចមួយនៅទីនោះ ។

ត៊្លិបបានគិតបន្តិច ហើយបានចូលនៅក្នុងជង្រុកដាក់របស់មិនត្រូវការដែលនៅក្រោមជណ្ដើរ ហើយបានក្រឡេកមើលជុំវិញខ្លួន ឃើញថាពុំមានអ្នកណាម្នាក់នៅទីនេះទេ ។ ពេលរៀបនឹងបើកកញ្ចប់អំណោយមើល ត៊្លិបបាននឹកឃើញនូវអ្វីដែលម្ដាយខ្លួនបានប្រាប់ខ្លួនថា៖ "អល់ឡោះហ្វ៍ជាអាុលីម ។"

ត៊្លិបបានត្រឡប់មករកម្ដាយខ្លួនវិញ ដោយពុំបានបើកកញ្ចប់អំណោយទេ ។ ម្ដាយត៊្លិបបានសួរត៊្លិបថា៖ "ហេតុអ្វីកូនឯងមិនបើកកញ្ចប់អំណោយ ?"

ត៊្លិបឆ្លើយថា៖ "ព្រោះមិនមានកន្លែងណាមួយដែលអល់ឡោះហ្វ៍មិនអាចមើលខ្ញុំឃើញទេ ។ ព្រះអង្គទ្រង់ញាណអ្វីៗសព្វគ្រប់ ព្រះអង្គជាអាុលីម ។"

**កិច្ចការសិស្ស ៥**

អល់ឡោះហ្វជាអាលីម ព្រះអង្គទ្រង់ញាណអ្វីៗគ្រប់សព្វ ។

តើអ្នកអាចរកឃើញកន្លែងណាមួយដែលពុំមានអ្នកណាអាចមើលឃើញអ្នកទេ ?
____________________________________________

តើអ្នកណាមើលឃើញអ្នកគ្រប់ទីកន្លែង ?________________________

ចូរផាត់ព័ណ៌លើកញ្ចប់អំណោយដែលម្តាយត្វ័លិបបានឲ្យត្វ័លិប ។



ម្តាយត្វ័លិបបានឲ្យត្វ័លិបបើកកញ្ចប់អំណោយ ព្រោះត្វ័លិបជាកូនចេះ ។

ចូរគូរអ្វីដែលមាននៅក្នុងកញ្ចប់អំណោយនេះ តាមការយល់ឃើញរបស់អ្នក ។

**មេរៀនទី ៦**

# ហៃ្យ (الحي)

អល់ឡោះហ្វ៍ជា **ហៃ្យ** - ព្រះអង្គទ្រង់គង់ព្រះជន្មនៅ ព្រះអង្គមិនសោយព្រះទិវង្គតឡើយ ។

យើងរាល់គ្នារមែងតែស្លាប់ ពេលយើងស្លាប់ យើងត្រឡប់ទៅឯអល់ឡោះហ្វ៍វិញ ។

បន្ទាប់ពីនោះ ព្រះអង្គនឹងដាក់យើងក្នុងឋានសួគ៌ឬក្នុងឋាននរក តាមតែយើងបានប្រព្រឹត្តិល្អឬអាក្រក់ ។

ប្រសិនបើអល់ឡោះហ្វ៍ទ្រង់សោយព្រះទិវគ្គតដែរនោះ យើងមិនអាចត្រឡប់ទៅឯព្រះអង្គវិញបានទេ ។ ដូច្នេះអល់ឡោះហ្វ៍មិនសោយព្រះទិវង្គតឡើយ ។

ថ្ងៃមួយ ត៌្លិបនិងឪពុកម្ដាយគិតនៅកំសាន្តឆ្នេរសមុទ្របីថ្ងៃ ។

មុននឹងចេញទៅកំសាន្តសមុទ្រ ពួកគាត់ចាត់ចែងឲ្យមានអ្នកណាម្នាក់ចាំឲ្យចំណីត្រីក្រឹមរបស់ត៌្លិប ពុំនោះទេវានឹងស្លាប់ជាមិនខាន ។

ម្ដាយត៌្លិបបានប្រាប់ថាត្រីក្រឹមត្រូវការថែរក្សាជាចាំបាច់ ដើម្បីវានឹងរស់រានមានជីវិត ។ គាត់បានសួរត៌្លិបថាតើអ្នកណាថែរក្សាពួកគាត់ ? ត៌្លិបបានឆ្លើយថា៖ "អល់ឡោះហ្វ៍ ។"

ម្ដាយត៌្លិបបានប្រាប់ទៀតថា បើមិនមានអល់ឡោះហ្វ៍ទេ អ្វីៗទាំងអស់ក្នុងលោកនេះនឹងស្លាប់អស់ ។ ដោយភ័ព្វល្អ អល់ឡោះហ្វ៍ទ្រង់ឃ្លាំយាមសព្វគ្រប់ ហើយព្រះអង្គចាត់ចែងឲ្យសព្វគ្រប់មានដំណើរការល្អដូចគម្រោងទុក ។

អស់ទ្បោះហ្វ៍ជាហ្វៃ ព្រះអង្គទ្រង់គង់ព្រះជន្មនៅ ព្រះអង្គនឹងគង់ព្រះជន្មនៅរៀងរហូត ។

**កិច្ចការសិស្ស ៦**

អល់ឡោះហ្វ៍ជាប្ចៃ ព្រះអង្គទ្រង់គង់ព្រះជន្មនៅ ព្រះអង្គនឹងគង់ព្រះជន្មនៅរៀងរហូត ។



ពេលត៊្លិបស្លាប់
ត៊្លិបនឹងវិលត្រឡប់
ទៅឯអល់ឡោះហ្វ៍វិញ

# អល់ឡោះហ្វ៍

| ឋានសួគ៌ | ឋាននរ |
| --- | --- |
| | |

ចូរគូរឋានសួគ៌និងឋាននរកដោយស្មាន ។

ចូរគូសខ្វែងនៅលើឋាននរក ព្រោះត៊្លិបជាក្មេងមុស្លីមល្អ ។

**មេរៀនទី ៧**

# មូរីដុ (المريد)

អល់ឡោះហ្វ៍ជា **មូរីដុ** - ព្រះអង្គធ្វើអ្វីស្រេចតែព្រះអង្គចង់ ។

អល់ឡោះហ្វ៍បានបង្កើតអ្វីៗសព្វគ្រប់ ដូច្នេះអ្វីៗសព្វគ្រប់ជារបស់ព្រះអង្គ ។ ព្រះអង្គចង់ធ្វើអ្វីដែលព្រះអង្គសព្វព្រះហឫទ័យ ដោយមិនសួរអ្នកណាឡើយ ។

ដូចគ្នាដែរ ប្រសិនបើប្រដាប់លេងជារបស់ក្មេងណាម្នាក់ ក្មេងនោះមិនបាច់សូមអនុញ្ញាតលេងជាមួយប្រដាប់លេងនោះពីអ្នកដទៃទេ ។ ប្រសិនបើប្រដាប់លេងនោះជារបស់អ្នកដទៃ ក្មេងនោះត្រូវសូមអនុញ្ញាតសិន ។

វត្ថុសព្វគ្រប់និងសត្វលោកទាំងអស់ជារបស់អល់ឡោះហ្វ៍ ព្រោះអល់ឡោះហ្វ៍បានបង្កើតអ្វីៗទាំងអស់ ។ ដូច្នេះអល់ឡោះហ្វ៍ធ្វើអ្វីស្រេចតែព្រះអង្គចង់ ។

អ្វីដែលអល់ឡោះហ្វ៍សាងមកសុទ្ធតែល្អនិងសមសួន ។ ព្រះអង្គមិនសាងអ្វីដែលអាក្រក់ទេ ។

ត៉្វលិបចង់បានឆ្មាមួយ ។ វាបួងសួងសូមអល់ឡោះហ្វ៍ តែវាមិនបានឆ្មាទេ ។ ត៉្វលិបតូចចិត្តព្រោះវាគិតថាអល់ឡោះហ្វ៍មិនបានស្ដាប់សំណូមពរវាទេ ។

ថ្ងៃមួយត៉្វលិបបានទៅលេងផ្ទះមិត្តវា ។ ត៉្វលិបសប្បាយចិត្តណាស់ព្រោះមិត្តវាមានឆ្មាមួយ ។ ត៉្វលិបលេងជាមួយឆ្មា ព្រមទាំងប៉ងថាអល់ឡោះហ្វ៍នឹងស្ដាប់សំណូមពរវាហើយព្រះអង្គឲ្យឆ្មាមួយមកវា ។ ភ្លាមៗនោះ ស្រាប់តែវាមិនស្រួលខ្លួន ។ វាចាប់ផ្ដើមក្អក កណ្ដាស់ ហើយពិបាកដកដង្ហើម ។

គេបានយកត៍្លិបទៅមន្ទីរពេទ្យជាបន្ទាន់ ។ គ្រូពេទ្យបានឲ្យថ្នាំមកព្យាបាលវា ។

លុះបានស្រួលខ្លួនបន្តិច ម្ដាយត៍្លិបបានពន្យល់ប្រាប់វានូវអ្វីដែលបានកើតឡើង ។ គាត់បានប្រាប់ត៍្លិបថាសត្វឆ្មាធ្វើឲ្យក្នុងខ្លួនត៍្លិបមានប្រតិកម្មមិនល្អ ។

ត៍្លិបបានសួរថាតើបានសេចក្ដីថាអ្វី ។ ម្ដាយត៍្លិបបានពន្យល់ថា ក្នុងខ្លួនត៍្លិបមិនអាចទទួលយកបាននូវអ្វីមួយពីខ្លួនសត្វឆ្មាទេ ប្រហែលជារោមឆ្មាដែលជ្រុះមកច្រើនហើយរោមនោះជាប់នឹងខ្លួនត៍្លិប ពេលត៍្លិបលេងជាមួយឆ្មា ។

ត៍្លិបញញឹម ។ ម្ដាយត៍្លិបបានសួរថាហេតុអ្វីត៍្លិបញញឹម ត៍្លិបបានឆ្លើយថាវាទើបតែយល់ថាការពិតអល់ឡោះហ្វស្តាប់សត្វលោកទាំងអស់ ហើយព្រះអង្គធ្វើអ្វីដែលល្អសម្រាប់អ្នកទាំងអស់គ្នា ។

ត៍្លិបបានប្រាប់ម្ដាយថាវាបានបួងសួងសូមឆ្មាពីអល់ឡោះហ្វយូរមកហើយ ព្រោះតែវាមិនបានឆ្មាមួយបានជាវាគិតថាអល់ឡោះហ្វមិនបានស្តាប់សំណូមពរវា ។ តែការពិតអល់ឡោះហ្វបានស្តាប់សំណូមពរវា ក៏ប៉ុន្តែព្រោះតែសត្វឆ្មាមិនល្អសម្រាប់ខ្លួនវាបានជាអល់ឡោះហ្វមិនបំពេញបំណងវា ។

ម្ដាយត៍្លិបបានថាអល់ឡោះហ្វនឹងប្រទានស្ទាវ៉ាប់ (ثواب) ឲ្យត៍្លិបវិញ ព្រោះព្រះអង្គមិនបានបំពេញបំណងត៍្លិប អ្វីដែលត៍្លិបមិនបានដូចបំណងនោះជាការប្រសើរសម្រាប់ត៍្លិប ។

អល់ឡោះហ្វជា **មូរីដុ** - ព្រះអង្គធ្វើអ្វីស្រេចតែព្រះអង្គចង់ តែអ្វីដែលព្រះអង្គធ្វើនោះល្អជានិច្ច ។

## កិច្ចការសិស្ស ៧

អល់ឡោះហ្វាជាម្ចាស់ ព្រះអង្គធ្វើអ្វីស្រេចតែព្រះអង្គ តែអ្វីដែលព្រះអង្គធ្វើនោះល្អជានិច្ច មិនអាក្រក់ឡើយ ។

គ្ល័លិបប៉ងចង់បានឆ្មា តែគ្ល័លិបមិនបានឆ្មាដូចបំណងទេ ព្រោះមិនបានឆ្មាប្រសើរសម្រាប់គ្ល័លិប ។



ចូរគូររូបអ្វីដែលអ្នកប៉ងចង់បានតែមិនបានដូចបំណងទៅវិញ ។

**មេរៀនទី ៨**

# មុដ្ឌរិក (المودريك)

អល់ឡោះហ្វ៎ជា **មុដ្ឌរិក** - ព្រះអង្គទ្រង់សវនាការ ព្រះអង្គទ្រង់ទស្សនាការសព្វគ្រប់ ។

អល់ឡោះហ្វ៎អាចមើលឃើញនិងស្តាប់ឮសព្វគ្រប់ តែព្រះអង្គមិនបាច់មានភ្នែក មានត្រចៀកដូចយើងទេ ។

ពុំមានកន្លែងលាក់បំពួនណាមួយដែលអល់ឡោះហ្វ៎មើលមិនឃើញទេ ។

អ្នកមិនអាចនិយាយអ្វីដែលអល់ឡោះហ្វ៎មិនអាចឮបាននោះទេ ទោះបីអ្នកខ្សឹបតិចប៉ុណ្ណាក៏ដោយ ។

ត៉្វលិបបានសូមម្តាយចេញទៅលេងខាងក្រៅផ្ទះ ។ ម្តាយត៉្វលិបយល់ព្រម តែត៉្វលិបត្រូវរៀបទុកដាក់ប្រដាប់លេងនៅក្នុងបន្ទប់ឲ្យមានរបៀបរៀបរយសិន ។ ត៉្វលិបចង់ទៅភ្លាមៗ ព្រោះខ្លាចយឺតពេល ។

ត៉្វលិបបានឡើងទៅក្នុងបន្ទប់វា ដើម្បីរៀបចំឲ្យមានរបៀបរៀបរយ ។ ត៉្វលិបបានបិទទ្វារដើម្បីកុំឲ្យម្តាយវាឮវា បន្ទាប់មកត៉្វលិបបាននិយាយតិចៗថាម្តាយវាកាចណាស់ ។

វាបានឈប់និយាយភ្លាមព្រោះវានឹកឃើញថា ទោះបីម្តាយវាមិនអាចឮវានិយាយក៏ដោយតែអល់ឡោះហ្វ៎ឮវា ហើយត៉្វលិបដឹងច្បាស់ថាអល់ឡោះហ្វ៎មិនសព្វព្រះហឫទ័យវានិយាយអាក្រក់អំពីម្តាយវាទេ ។

ត៉្វលិបបានត្រឡប់ទៅរកម្តាយវាវិញ ហើយបានថើបម្តាយដោយសូមទោសម្តាយ

ដែលវាបានខឹងគាត់ ព្រោះត្ហ៊ុលិបដឹងថាម្ដាយវាមានបំណងល្អចំពោះវា ។

អល់ឡោះហ្វ៍ជា **មុជ្ជីវិក** - ព្រះអង្គទ្រង់សវនាការ ព្រះអង្គទ្រង់ទស្សនាការសព្វគ្រប់ ។

## កិច្ចការសិស្ស ៨

អល់ឡោះហ្ទ៍ជា **មុជ៉ូរិក** - ព្រះអង្គទ្រង់សវនាការ ព្រះអង្គទ្រង់ទស្សនាការសព្វគ្រប់ ។ តែព្រះអង្គមិនមានភ្នែក មិនមានត្រចៀកទេ ។

យើងមិនអាចមើលឃើញដោយគ្មានភ្នែកទេ ។



យើងមិនអាចស្តាប់ឮដោយគ្មានត្រចៀទេ ។



ចូរផាត់ព័ណ៌លើរូបដោយអរព្រះគុណអល់ឡោះហ្ទ៍ ដែលព្រះអង្គបានប្រទានភ្នែកនិងត្រចៀកឲ្យអ្នក ។

**មេរៀនទី ៩**

# មូតាកាល់លិម (المتكلم)

អល់ឡោះហ្វ៍ជា **មូតាកាល់លិម** - ព្រះអង្គអាចធ្វើឲ្យអ្នកណាមួយ ឬអ្វីមួយនិយាយបាន ស្រេចតែព្រះអង្គទ្រង់មានព្រះបំណង ។

អល់ឡោះហ្វ៍អាចធ្វើឲ្យដើមឈើចេះនិយាយ ព្រះអង្គអាចធ្វើឲ្យដុំថ្មចេះនិយាយ ។

ព្រះអង្គអាចធ្វើឲ្យវត្ថុសព្វគ្រប់ចេះនិយាយបាន ទោះបីវត្ថុនោះមិនមានជីវិតក៏ដោយ ។ ព្រោះព្រះអង្គបានបង្កើតអ្វីៗសព្វគ្រប់ ព្រះអង្គខ្លាំងពូកែបំផុត ។

អល់ឡោះហ្វ៍អាចធ្វើឲ្យអ្វីមួយចេះនិយាយ ស្រេចតែព្រះអង្គទ្រង់មានព្រះបំណង ។

ឧទាហរណ៍ពិតប្រាកដដែលបញ្ជាក់ឲ្យដឹងថា អល់ឡោះហ្វ៍បានធ្វើឲ្យវត្ថុគ្មានជីវិតចេះនិយាយនោះគឺ ព្រះសាស្តាមូហាំម៉ាដ់ﷺនិងដុំថ្ម ។

ពួកអ្នកស្រុកម៉ាក់កាស់ហ្វ៍បានសូមឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺបញ្ជាក់ថា ព្រះអង្គជាព្រះសាស្តារបស់អល់ឡោះហ្វ៍ពិតមែន ។

ព្រះសាស្តាចុងក្រោយបង្អស់របស់យើង គឺព្រះសាស្តាមូហាំម៉ាដ់ﷺបានរើសដុំថ្មពីរបីដុំមកដាក់ក្នុងដៃព្រះអង្គ ដុំថ្មទាំងនោះក៏បាននិយាយនៅចំពោះមុខមហាជន ។

ដុំថ្មបានអះអាងថា៖ "មូហាំម៉ាដ់ជាព្រះសាស្តារបស់អល់ឡោះហ្វ៍ ។"

មនុស្សទាំងអស់ដឹងច្បាស់ថាដុំថ្មជាវត្ថុគ្មានជីវិត វាមិនមានមាត់សម្រាប់និយាយទេ តែដុំថ្មទាំងនោះចេះនិយាយ ព្រោះអល់ឡោះហ្វ៍បានបញ្ជាឲ្យពួកវានិយាយ ។

អល់ឡោះហ្វជា ម្ចាស់ការលិម - ព្រះអង្គអាចធ្វើឲ្យអ្វីមួយចេះនិយាយ ស្រេចតែព្រះអង្គទ្រង់មានព្រះបំណង ។

## កិច្ចការសិស្ស ៩

អល់ឡោះហ្ទ៍ជា **មូតាកាល់លិម** - ព្រះអង្គអាចធ្វើឲ្យអ្វីមួយចេះនិយាយស្រេចតែលើព្រះអង្គ ។

ចូរនិយាយប្រាប់ម៉ែនិងពុករឿងព្រះសាស្ដា គឺព្រះសាស្ដាមូហាំម៉ាដ្ទ៉ﷺ និងដុំថ្មចេះនិយាយ ។




ចូរផាត់ព័ណ៌លើរូប ។

**មេរៀនទី ១០**

# ស្វ៍ឌិក្វ (الصادق)

អល់ឡោះហ្វ៍ជា **ស្វ៍ឌិក្វ** - ព្រះអង្គមានព្រះសច្ចធម៌ ។

អល់ឡោះហ្វ៍មិនភូតភរឡើយ ។

អល់ឡោះហ្វ៍ធ្វើតាមពាក្យសន្យាជានិច្ច ។

ម្ដាយត៊្វលិបបានប្រាប់ត៊្វលិបថា និយាយការពិតសំខាន់ណាស់ ។ គាត់បាននិយាយរឿងក្មេងម្នាក់ដែលចេះតែស្រែកបង្កក់ឲ្យគេយល់ខុសដូចតទៅគឺៈ

មានក្មេងប្រុសម្នាក់ ឪពុកវាបានឲ្យវាឃ្វាលចៀម ។ មួយថ្ងៃៗវាអង្គុយតែឃ្វាលចៀម ។ ព្រោះតែវាអផ្សុកពេកបានជាវាគិតបញ្ឆោតគេឯងជាល្បែងលេងសើច ។

វាបានស្រែកថាៈ "ឆ្កែព្រៃ ! ឆ្កែព្រៃ !" ខ្លាំងៗ លុះឪពុកវានិងអ្នកស្រុកបានឮ ក៏បានរត់មកជួយវានៅឯលើទួល ។

មកដល់លើទួល ពុំបានឃើញមានឆ្កែព្រៃទេ ឃើញតែក្មេងប្រុសនោះកំពុងតែសើចក្អាកក្អាយ ។

គេខឹងណាស់ ហើយបានប្រាប់វាថានិយាយភូតភរមិនល្អទេ ។

ស្អែកឡើង ក្មេងនេះត្រូវឃ្វាលចៀមទៀត ហើយបានគិតនឹងលេងបោកបញ្ឆោតគេទៀត ។ ដូចថ្ងៃមុនដែរ អ្នកស្រុកបានរត់មកជួយវា តែបានឃើញតែការបោកបញ្ឆោត ។

ថ្ងៃទីបី ពេលដែលក្មេងរូបនេះបានទៅលើទួលដើម្បីឃ្វាលចៀម ឆ្កែព្រៃបានមកទីនោះមែន ។ ក្មេងនេះក៏បានស្រែកខ្លាំងៗឲ្យគេជួយ តែពុំមានអ្នកណាមកជួយវាទេ ព្រោះគេគិតថានេះជាការបោកបញ្ឆោតរបស់វាទៀតហើយ ។ ឆ្កែព្រៃក៏បានស៊ីក្មេងនេះ ។

ម្ដាយត្រូលិបបានពន្យល់វាថា បើវាកុហកគេមួយដង គេនឹងមិនព្រមជឿវាងាយៗទៀតទេ ។

គាត់បាននិយាយបន្តទៀតថា ដូច្នេះហើយបានជាសំខាន់ណាស់ដែលព្រះសាស្ដា عليهم السلام គ្រប់រូបនិងអ៊ីមុាំ عليهم السلام គ្រប់រូបមិននិយាយកុហកជាដាច់ខាតមួយជីវិតព្រះអង្គ ដើម្បីនឹងកុំឲ្យមនុស្សអាចនិយាយបានថាព្រះអង្គមិនបាននិយាយការពិតទេ ។

ពេលអល់ឡោះហ្ទ៍ عز وجل មានព្រះបន្ទូលថា បណ្ដាព្រះសាស្ដា عليهم السلام និងបណ្ដាអ៊ីមុាំ عليهم السلام ត្រូវតែកាន់ពាក្យសច្ចៈនោះ គឺដូច្នេះមែន មិនកុហកទេ ។

អល់ឡោះហ្វ៍ជា ស្វ៍ឌិក្វ - ព្រះអង្គមានព្រះសច្ចធម៌ ។

**កិច្ចការសិស្ស ១០**

អល់ឡោះហ្វជា ស៊្ហឹឌិក្វ - ព្រះអង្គមានព្រះសច្ចធម៌ ។

ចូរអ្នកនិយាយរឿងក្មេងម្នាក់ដែលចេះតែស្រែកបង្កកឲ្យគេយល់ខុសឲ្យម្ដាយ និង ឪពុកអ្នកស្ដាប់ ។

ចូរផាត់ព័ណ៌លើរូបឆ្កែព្រៃ និងប្រាប់ម្ដាយនិងឪពុកថាហេតុអ្វីអ្នកមិនត្រូវនិយាយកុហកទេ ។





**មេរៀនទី ១១**

# កាយវិការស្វ័ទឡាត់

កាយវិការស្វ័ទឡាត់ប្រុសនិងស្វ័ទឡាត់ស្រីខុសគ្នាបន្តិច ។

ត្ថ៍លិបនិងត្ថ៍លីបាស្វ៉ ប្អូនស្រី រំលឹកឡើងវិញនូវកាយវិការស្វ័ទឡាត់ ដើម្បីអ្នកនឹងបាន ឃើញថាខុសគ្នាត្រង់ណាខ្លះ ហើយដើម្បីនឹងឲ្យអ្នកចេះធ្វើត្រឹមត្រូវ ។

**គ្វីយ៉ាម** - គឺវិធីឈរត្រង់ខ្លួនពិសេសក្នុងពេលបំពេញស្វ័ទឡាត់ ។

| ត្ថ៍លិប | ត្ថ៍លីបាស្វ៉ |
|---|---|
| ១) កន្ធែកប្រអប់ជើងបន្តិច | ១) ប្រអប់ជើងជិតគ្នា |
| ២) សំយុងដៃតាមដងខ្លួន | ២) ---------- |
| ៣) ម្រាមដៃរួមគ្នា | ៣) ---------- |
| ៤) ដាក់ភ្នែក (មើលទៅឯទូរបាស្វ៉) | ៤) ---------- |
| ៥) ទម្លាក់ស្មា | ៥) ---------- |

**តាក់ប៊ីរ៉ទុល អិះហ្រ៉ាំម** - ជាការសូត្រថា អល់ឡ៉ហ្វ អាក់បារ ទីមួយដែលអ្នកទាំងអស់ គ្នាសូត្រនៅក្នុងស្វ័ទឡាត់ ។ គេសូត្រ តាក់ប៊ីរ៉ទុល អិះហ្រ៉ាំម នេះក្រោយពីនៀតរួច (គឺ ក្រោយពីបាននឹកក្នុងចិត្តថាចង់ធ្វើអ្វី និងធ្វើដើម្បីអ្នកណា) ។

| ត្ថ៍លិប | ត្ថ៍លីបាស្វ៉ |
|---|---|
| ១) កន្ធែកប្រអប់ជើងបន្តិច | ១) ប្រអប់ជើងជិតគ្នា |
| ២) លើកដៃដល់ត្រចៀក (មេដៃនៅក្រោយត្រចៀក) | ២) -------------- |
| ៣) ដាក់ភ្នែក (មើលទៅឯទូរបាស្វ៉) | ៣) -------------- |

**រុគុអ៍** - គឺការឱន ចាត់ទុកថាត្រូវបើពាក់កណ្ដាលខ្លួនអ្នកកោង ។

| ត៍្លិប | ត៍្លីបាស៊ុ |
|---|---|
| ១) កន្ទែកប្រអប់ជើងបន្តិច | ១) ប្រអប់ជើងជិតគ្នា |
| ២) ដាក់ដៃលើជង្គង់ | ២) -------- |
| ៣) សម្លឹងមើលក្រោម (មើលប្រឡោះជើង) | ៣) -------- |
| ៤) សន្ទឹងជើង (ជើងត្រង់) | ៤) មិនសន្ទឹងជើងទេ |
| ៥) ខ្នងរាបស្មើ | ៥) -------- |

**សាចុ់ដ្វាស៊ុ** - គឺពេលគេដាក់ក្បាលលើផ្ទៃកម្រាល (ក្រាប) ។ បាតដៃអ្នក ជង្គង់អ្នក និង មេជើងអ្នកត្រូវប៉ះផ្ទៃកម្រាលដែរ ។ ក្នុងរ៉ក់អ៊ាត់(ركعة)នីមួយៗមានពីរស៊្វយ៊ូដ កាត់ចែកដោយយ៊ូលូសមួយ ។

| ត៍្លិប | ត៍្លីបាស៊ុ |
|---|---|
| ១) ប្រអប់ជើងឃ្លាតគ្នាបន្តិច (មេជើងប៉ះផ្ទៃកម្រាល) | ១) ប្រអប់ជើងជិតគ្នា (មេជើងប៉ះផ្ទៃកម្រាល) |
| ២) ភ្នែកសម្លឹងទៅចុងច្រមុះ | ២) ------------ |

ម្រាមដៃជិតគ្នា តម្រង់ទៅរកគី្ឫបឡាស៊ុ ក្បែរត្រចៀក

| ត៍្លិប | ត៍្លីបាស៊ុ |
|---|---|
| ៣) កែងដៃមិនប៉ះផ្ទៃកម្រាលទេ (ឃ្លាតពីដងខ្លួនបន្តិច) | ៣) កែងដៃប៉ះផ្ទៃកម្រាល (មិនឃ្លាតពីដងខ្លួនទេ) |

**យ៊ូលុស** - គឺការអង្គុយ ។

| ត៍្លិប | ត៍្លីបាស៊ុ |
|---|---|
| ១) ដាក់ប្រអប់ជើងស្ដាំលើប្រអប់ជើងឆ្វេង | ១) ------------ |
| ២) ដាក់ដៃលើភ្លៅ | ២) ------------ |
| ៣) ភ្នែកសម្លឹងមើលទៅឯទូរបាស៊ុ | ៣) ------------- |

**គ្នូទូត** - គឺការលើកដៃឡើង ដោយលាតប្រអប់ដៃឆ្ពោះទៅឯមេឃ ។ ត្រូវប្រព្រឹត្តនៅក្នុងរ៉ក់អ្កុស្ទ៍ ទី ២ ពេលបំពេញស្វ៍ឡាត្ទ៍ នៅពេលកំពុងឈរមុនរ្វ៍គុអ៊ុំ ។

ត្ក៏លិប

១) ប្រអប់ជើងឃ្លាតគ្នាបន្តិច

២) ដាក់ដៃចំពីមុខ បាតដៃលាតទៅឯមេឃ

៣) ភ្នែកសម្លឹងមើលប្រអប់ដៃ

ត្ក៏លីបាស្ទ៍

១) ប្រអប់ជើងជិតគ្នា

ប្រអប់ដៃនិងម្រាមដៃជាប់គ្នា

៣) ------------------

**កិច្ចការសិស្ស ១១**

# កាយវិការក្នុងស្វ៍ឡាត់



តាក់បីរ៉ទុល អិះប្រ៉ារ៉ម | គ្ញីយ៉ាម | រូគុអ៊ុ | គ្ញីយ៉ាម | សាច់ដ្វាស៊ុ | យ្ជុលុស | សាច់ដ្វាស៊ុ



យ្ជុលុស | គ្ញីយ៉ាម | គុនូត | រូគុអ៊ុ | គ្ញីយ៉ាម | សាច់ដ្វាស៊ុ | យ្ជុលុស



សាច់ដ្វាស៊ុ | យ្ជុលុស (ចប់)



តាក់បីរ៉ទុល អិះប្រ៉ារ៉ម | គ្ញីយ៉ាម | រូគុអ៊ុ | គ្ញីយ៉ាម | សាច់ដ្វាស៊ុ | យ្ជុលុស | សាច់ដ្វាស៊ុ


ឃូលុស


គីយ៉ាម


គូនូត


រុគុអ៊ំ


គីយ៉ាម


សាច់ដ្ងាស់


ឃូលុស


សាច់ដ្ងាស


ឃូលុស (ចប់)

**មេរៀនទី ១២**

# វូឌុអ៊ុ - អធិប្បាយ

វូឌុអ៊ុ (وُضوء) គឺការលាងសម្អាតខ្លួនពិសេសមុនស្ឡាត់ ដែលព្រះសាស្តាﷺយើងបានបង្គាត់យើង បន្ទាប់ពីព្រះអង្គបានត្រឡប់មកពីមិអ៊្រ៉ាច្ច(معراج)វិញ ។

នៅពេលមិអ៊្រ៉ាច្ច(معراج) ព្រះសាស្តាﷺបានយកទឹកវូឌុអ៊ុ (وُضوء) ជាមួយទឹកស្ទឹងឋានសួគ៌ ។

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនៅក្នុងគួរអាន ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ អាយ៉ាស់ ៦ ថា៖

*"បណ្ដាអ្នកមានសទ្ធាអើយ កាលបើពួកអ្នករៀបចំខ្លួនធ្វើនមស្ការ [ចូរពួកអ្នកធ្វើពិធីជម្រះកាយគឺ៖] ចូរពួកអ្នកលាងមុខពួកអ្នក និងលាងដៃដល់ (ព្រមទាំង) កែងដៃពួកអ្នក ចូរពួកអ្នកយកដៃទទឹកជូតលើក្បាលនិងលើជើងពួកអ្នកដល់កជើង... ។" (៥:៦)"*

វូឌុអ៊ុមិនត្រឹមតែចាំបាច់សម្រាប់ស្ឡាត់ទេ តែចាំបាច់ដែរសម្រាប់៖

- ត៉្វាហ្វ (طواف) វ៉ាជិបនៅពេលបំពេញពិធីហ្ជាច្ច ។
- ប៉ះអក្សរសំណេរក្នុងព្រះមហាគម្ពីរគួរអាន ។
- ប៉ះព្រះនាមអល់ឡោះហ្ទ៍ﷻ និងបុគ្គលបរិសុទ្ធ (ម៉ាក់ស៊្ហូមីន) ទាំង ១៤ អង្គ عليهم السلام ។

យកល្អឲ្យមានទឹកវូឌុអ៊ុពេល៖

- មុនចូលដំណេក ។
- មុនទៅកាន់អ៊ីម៉ាំបារ៉ា (امامبارا ឬ ហ៊្វូសៃនីយ៉ាស់ حسينية) ពោលគឺ ផ្ទះរបស់

អ៊ីម៉ាំ ។

- ពេលខឹង (ព្រោះវាធ្វើឲ្យរសាយកំហឹង) ។
- គ្រប់ពេល ។

មុននឹងយកទឹកវូឌូអ៊្វ អ្នកត្រូវដឹងថាប៉ែកអវយវៈដែលត្រូវលាងសម្អាតនោះ (មុខ ដៃ ក្បាល ជើង) ត្រូវជ្រះស្អាតជាមុនសិន កុំឲ្យមានអ្វីមួយបិទបាំងវាបណ្តាលឲ្យទឹកមិនអាចជ្រាបចូលបាន ។ ឧទាហរណ៍ដូចជាមនោសិលា (ឬ ម្នាងសិលា) ថ្នាំលាបក្រចកចិញ្ចៀន នាឡិកា ស្រោម ជើង...ជាដើម ។

# កិច្ចការសិស្ស ១២

ចូរសរសេរនៅក្នុងរង្វង់មូលទាំងបួនខាងក្រោមនេះ ថាហេតុអ្វីអ្នកត្រូវមានទឹករំឧ្មុំ (វ៉ាឃ្យិប) ។



ចូរសរសេរនៅក្នុងរង្វង់មូលទាំងបួនខាងក្រោមនេះ ថាយកល្អអ្នកគួរតែមានទឹករំឧ្មុំ (ស្វ៊ូណាត្ត៉ុ) ។



**មេរៀនទី ១៣**

# វូឌុអ៍ - ទង្វើស៊ូណាត់

វូឌុអ៍ ចែកជាពីរគឺ៖
១) ទង្វើស៊ូណាត់ (سنة) - មិនមែនជាការចាំបាច់ទេ តែបើធ្វើនឹងបានរង្វាន់ (ثواب) ច្រើន ។
២) ទង្វើវ៉ាញិប - ជាការចាំបាច់ បើមិនបានធ្វើទេ វូឌុអ៍ត្រូវមោឃៈ (គឺខូច) ។

អ្នកគប្បីធ្វើទាំងពីរ ទាំងទង្វើស៊ូណាត់ ទាំងទង្វើវ៉ាញិប ដើម្បីទទួលបាននូវរង្វាន់ (ثواب) ជាអតិបរមា ។

ទង្វើស៊ូណាត់គឺ៖

១) លាងប្រអប់ដៃទាំងពីរ (ពីរដង) ។



២) លាងមាត់ (ខ្ពុរមាត់) ៣ ដង ។



៣) លាងច្រមុះ (ស្រូបទឹកទៅក្នុងរន្ធច្រមុះ) ៣ ដង ។



៤) ការលាងដៃ សម្រាប់មនុស្សប្រុសនិងមនុស្សស្រី ខុសគ្នាបន្តិចបន្តួច ។ សម្រាប់មនុស្សស្រី - ចាក់ទឹកលើពោះដៃត្រង់គន្លាក់កែងដៃ



## កិច្ចការសិស្ស ១៣

នៅខាងក្រោមនេះគឺរូបខ្ចុអ៊ុំស៊ូណាតុំ ។ ចូរផាត់ព័ណ៌លើរូបនិងសរសេរត្រូវលាងប៉ុន្មានដង ។



________ដង ។



________ដង ។



________ដង ។

**មេរៀនទី ១៤**

# វូឌុអ៊ុ - ទង្វើវ៉ាយិ៊ប ៖ លាងមុខ

មុននឹងលាងមុខ អ្នកត្រូវប្រតិបត្តិទង្វើវ៉ាយិ៊បរបស់វូឌុអ៊ុ គឺនៀត (ﻧﻴّﺔ ពោលគឺ អ្វីដែលអ្នកចង់ធ្វើ និងដើម្បីអ្នកណា) ។

នៀត (ﻧﻴّﺔ) - អ្នកត្រូវថាៈ "ខ្ញុំយកទឹកវូឌុអ៊ុដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្វ៍ គូរបាត្វាន់ អ៊ីលឡុលឡោះហ្វ៍ ។"

បន្ទាប់មក វ៉ាយិ៊បឲ្យលាងមុខ ។ យកដៃស្តាំក្បង់ទឹក ហើយយកមកចាក់នៅលើថ្ងាសដោយចាប់ផ្តើមពីជើងសក់ (កន្លែងដែលសក់ដុះ) ។

អ្នកត្រូវជុសលាងបណ្តោយផ្ទៃមុខអ្នកទាំងស្រុង ។ ចាប់ផ្តើមពីខាងលើថ្ងាស (ពីជើងសក់) មកចប់នៅឯចុងចង្កា (កុំធ្វើចាប់ពីខាងក្រោមឡើងទៅលើឡើយ) ។



អ្នកត្រូវជុសលាងទទឹងផ្ទៃមុខអ្នកទាំងស្រុង ។ ធ្វើបែបនេះដោយលាតប្រអប់ដៃឲ្យធំ (ពីមេដៃទៅដៃកណ្តាល) ដូចត្ពំលិបធ្វើដែរ ។

ដើម្បីនឹងប្រាកដថាអ្នកលាងផ្ទៃទទឹងមុខអ្នកសព្វ អ្នកត្រូវយកដៃទទឹករបស់អ្នកមក

ជូតចាប់ពីរឹមផ្ទៃមុខទាំងសងខាង ។

លាងមុខមួយដងគ្រប់គ្រាន់ហើយ តែយកល្អឲ្យលាងពីរដង កុំឲ្យលើសពីពីរដង ។

**កិច្ចការសិស្ស ១៤**

បន្ទាប់ពីបាននៀតហើយ ត្រូវដុសលាងមុខ ។ ចូរផាត់ព៌ណលើរូបត្ម៉ុលិបដុសលាងមុខ ហើយចូរគូសមុខព្រួញដើម្បីបង្ហាញទិសដៅដែលត្ម៉ុលិបត្រូវប្រើដៃរបស់វា ។



ចូរគូសខ្សែក្រហាមនៅលើផ្ទៃមុខខាងក្រោមនេះ ដើម្បីបង្ហាញនូវប៉ែកដែលត្រូវដុសលាងក្នុងការយកទឹករ្វខ្នុអ៊ុំ ។



**មេរៀនទី ១៥**

# វូឌុអ៍ - ទង្វើវ៉ាយ៊ិប ៖ លាងដៃ

ទង្វើវ៉ាយ៊ិបក្នុងការយកទឹកវូឌុអ៍តទៅនេះគឺការលាងដៃ ។

ការលាងដៃគឺចាប់ពីកែងដៃរហូតដល់ចុងម្រាមដៃ ដោយចាក់ទឹកលើខ្នងដៃត្រង់គន្លាក់កែងដៃ ។

មុនដំបូង លាងដៃស្តាំ ដោយប្រើប្រអប់ដៃឆ្វេង ។ បន្ទាប់មក លាងដៃឆ្វេង ដោយប្រើប្រអប់ដៃស្តាំ ។

ត្រូវលាងមួយដង យកល្អលាងពីរដង កុំឲ្យលើសពីពីរដង ។



# កិច្ចការសិស្ស ១៥

ឲ្យប្រុសៗផាត់ព័ណ៌លើរូបត្រីលិបលាងដៃ ។ គូសមុខព្រួញដើម្បីបង្ហាញគោលដៅរបស់ប្រអប់ដៃដែលប្រើសម្រាប់ជុសលាង ។

ឲ្យស្រីៗផាត់ព័ណ៌លើរូបត្រីលីបាស្ទ់លាងដៃ ។ គូសមុខព្រួញដើម្បីបង្ហាញគោលដៅរបស់ប្រអប់ដៃដែលប្រើសម្រាប់ជុសលាង ។

លាងដៃស្តាំមុន





បន្ទាប់មកលាងដៃឆ្វេង





ស្ទីលណាត់លាងដៃខុសគ្នាត្រង់ណា សម្រាប់មនុស្សប្រុសនិងមនុស្សស្រី ?

**មេរៀនទី ១៦**

# វូឌុអ៊ - ទង្វើវ៉ាយិប ៖ ម៉ាសាស៊ុ

បន្ទាប់ពីការលាងមុខនិងដៃ គឺការជូត ដែលហៅថា ម៉ាសាស៊ុ (مسح) ។

ម៉ាសាស៊ុ (مسح) ធ្វើលើក្បាលនិងលើប្រអប់ជើងទាំងពីរ ។

ម៉ាសាស៊ុ (مسح) ក្បាលគឺ៖ ជូតក្បាល ដោយម្រាមដៃស្តាំបីដែលទទឹក ចាប់ពីពាក់កណ្តាលក្បាលមកដល់ចុងសក់ ដោយមិនប៉ះថ្ងាស ។

កុំឲ្យទឹកលើក្បាលប៉ះនឹងទឹកលើមុខ ។



ម៉ាសាស៊ុ (مسح) ជើងគឺ៖ ជូតប៉ែកលើប្រអប់ជើងស្តាំដោយម្រាមដៃស្តាំដែលទទឹក ចាប់ពីចុងម្រាមជើងរហូតដល់កជើង ។

បន្ទាប់មក ធ្វើដូចគ្នាជាមួយដៃឆ្វេងនិងជើងឆ្វេង ។



## កិច្ចការសិស្ស ១៦

ម៉ាសាស៊ុ (مسح) ក្បាល ។ ចូរផាត់ព័ណ៌លើរូបត៌្លិបធ្វើម៉ាសាស៊ុក្បាល ហើយគូសខ្សែខ្វែងត្រង់កន្លែងដែលម្រាមដៃមិនត្រូវទៅដល់ ។



ម៉ាសាស៊ុ (مسح) ជើង ។ ចូរផាត់ព័ណ៌លើរូបត៌្លិបធ្វើម៉ាសាស៊ុជើង ហើយគូសខ្សែក្រហមដើម្បីបង្ហាញនូវប៉ែកដែលម្រាមដៃជូតលើ ។



## មេរៀនទី ១៧

# វូឌុអ៊ុសរុប

(សាឡើងវិញ)

**ទង្វើស៊ូណាត់**



លាងដៃ ២ ដង



ខ្ពុរមាត់ ៣ ដង



លាងច្រមុះ ៣ ដង

**ទង្វើវ៉ាយិប**



លាងមុខ



លាងដៃ



ម៉ាសាស់ (مسح) ក្បាល



ម៉ាសាស់ (مسح) ជើង

# កិច្ចការសិស្ស ១៧

ចូរទន្ទេញឌូអាអ៍ (دُعَاء) ខាងក្រោមនេះគឺ៖




## ពេលចាប់ផ្តើមយកទឹកវូឌុអ៍

ដោយព្រះនាមអល់ឡោះហ្វ៍ និងដើម្បីអល់ឡោះហ្វ៍ ។ សូមថ្វាយសេចក្តីស្ញើចសរសើរចំពោះអល់ឡោះហ្វ៍ដែលបានធ្វើឲ្យទឹកបរិសុទ្ធ និងគ្មានណាយ៉ិស ។

## ពេលលាងប្រអប់ដៃ

ឱអល់ឡោះហ្វ៍! សូមព្រះអង្គទុកទូលព្រះបង្គំជាខ្ញុំនៅក្នុងចំណោមអ្នកដែលសូមអភ័យទោស និងដែលជាអ្នកបរិសុទ្ធជ្រះថ្លា ។

## ពេលខ្ពុរមាត់

ឱអល់ឡោះហ្វ៍! សូមព្រះអង្គមេត្តាអនុញ្ញាតឲ្យទូលព្រះបង្គំជាខ្ញុំអាចឆ្លើយតបបានយ៉ាងងាយស្រួលនៅថ្ងៃដែលទូលព្រះបង្គំជាខ្ញុំនឹងបានជួបព្រះអង្គ និងសូមព្រះអង្គមេត្តាស្រោយអណ្តាតទូលព្រះបង្គំជាខ្ញុំក្នុងការពោលសរសើរព្រះអង្គផង ។

**ពេលលាងច្រមុះ**

ឱអល់ឡោះហ្វ៍! សូមព្រះអង្គមេត្តាកុំផ្តាច់ទូលព្រះបង្គំជាខ្ញុំពីក្លិនក្រអូបរបស់ឋានសួគ៌ និងសូមព្រះអង្គមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំ បាននៅជាមួយបណ្តាអ្នកដែលនឹងបានហិតក្លិនក្រអូបរបស់ឋានសួគ៌ផង ។

**ពេលលាងមុខ**

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះមេត្តាឲ្យមុខទូលព្រះបង្គំជាខ្ញុំភ្លឺត្រចះត្រចង់នៅថ្ងៃដែលមុខទាំងឡាយនឹងខ្មៅ និងសូមព្រះអង្គព្រះមេត្តាកុំឲ្យមុខទូលព្រះបង្គំជាខ្មៅនៅថ្ងៃដែលមុខទាំងឡាយនឹងភ្លឺត្រចះត្រចង់ ។

**ពេលលាងដៃស្តាំ**

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះមេត្តាឲ្យបញ្ជីមកទូលព្រះបង្គំជាខ្ញុំក្នុងដៃស្តាំទូលព្រះបង្គំជាខ្ញុំ និងសិទ្ធិជ្រកនៅក្នុងឋានសួគ៌ជារៀងរហូតក្នុងដៃឆ្វេងទូលព្រះបង្គំជាខ្ញុំ ហើយសូមព្រះអង្គព្រះមេត្តាឲ្យការទូទាត់របស់ទូលព្រះបង្គំជាខ្ញុំងាយស្រួលផង ។

**ពេលលាងដៃឆ្វេង**

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះមេត្តាកុំដាក់បញ្ជីទូលព្រះបង្គំជាខ្ញុំក្នុងដៃឆ្វេងទូលព្រះបង្គំជាខ្ញុំនិងលើខ្នងទូលព្រះបង្គំជាខ្ញុំ ហើយកុំព្យួរបញ្ជីទូលព្រះបង្គំជាខ្ញុំលើកទូលព្រះបង្គំជាខ្ញុំ។ ទូលព្រះបង្គំជាខ្ញុំសូមជ្រកក្រោមការបីបាច់រក្សារបស់ព្រះអង្គ ដើម្បីនឹងបានរួចផុតពីភ្លើងនរក ។

**ពេលជូតក្បាល**

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះមេត្តាឡោមព័ទ្ធទូលព្រះបង្គំជាខ្ញុំដោយព្រះមេត្តាធម៌របស់ព្រះអង្គ ដោយព្រះខន្តីមេត្តារបស់ព្រះអង្គ និងដោយការអភ័យទោសរបស់ព្រះអង្គ ។

**ពេលជូតជើង**

ឱអល់ឡោះហ្វ៍! សូមព្រះអង្គព្រះមេត្តាឲ្យទូលព្រះបង្គំជាខ្ញុំរឹងប៉ឹងនៅលើស្ពានឋាន

សួគ៌នៅថ្ងៃដែលជើងទាំងឡាយនឹងរអិល ហើយសូមព្រះអង្គព្រះមេត្តាជួយទូលព្រះបង្គំជាខ្ញុំក្នុងការខិតខំធ្វើអំពើដែលសព្វព្រះហឫទ័យព្រះអង្គ ឱព្រះដ៏រុងរឿង ព្រះដ៏មានព្រះមហិទ្ធិឫទ្ធិអើយ !

**មេរៀនទី ១៨**

# វូឌូអ៊ុំសរុប

**(អនុវត្តន៍បង្ហាញ)**

ចូរនាំសិស្សទៅក្បែរអាងទឹក ហើយបង្ហាញសិស្សនូវរបៀបយកទឹកវូឌូអ៊ុំ ។

## កិច្ចការសិស្ស ១៨

ចូរគូរអ្វីដែលអ្នកបានឃើញ ពេលដែលគ្រូបានបង្ហាញអ្នកនូវរបៀបយកទឹកវូឌូអ៊ុំ ។

**មេរៀនទី ១៩**

# តាស់ប៊ិះហ្ហ៍

តាស់ប៊ិះហ្ហ៍ (تسبيح) ដែលយើងសូត្រក្រោយពីស្វ៉ឡាត់រួច ជាតាស់ប៊ិះហ្ហ៍ដែលគេស្គាល់ថាជាតាស់ប៊ិះហ្ហ៍របស់ប៊ីប៊ីហ្វាទី៍ម៉ាស់ អាស់-ស្ហាស់រ៉អ៊ុ عليها السلام ព្រោះព្រះនាងបានទទួលជាអំណោយមកពីព្រះបិតាព្រះនាង عليها السلام ព្រះសាស្តាមូហ្ហាំម៉ាដ់ ﷺ យើង ។

ប៊ីប៊ីហ្វាទី៍ម៉ាស់ عليها السلام ធ្លាប់តែប្រកបកិច្ចការធ្ងន់ក្នុងផ្ទះ ។ ព្រះបិតាព្រះនាង ព្រះសាស្តាមូហ្ហាំម៉ាដ់ ﷺ រមែងតែឃើញព្រះនាង عليها السلام ធ្វើការធ្ងន់ ។

ថ្ងៃមួយព្រះអង្គ ﷺ បានប្រាប់ព្រះនាង عليها السلام ថា ព្រះអង្គ ﷺ នឹងប្រទានឲ្យព្រះនាង عليها السلام នូវអ្វីមួយដែលប្រសើរលើសស្រីបម្រើក្នុងលោកនេះណាស់ ។

ព្រះអង្គ ﷺ បានប្រទានតាស់ប៊ិះហ្ហ៍ (تسبيح) ឲ្យព្រះនាង عليها السلام ។
ព្រះអង្គ ﷺ បានប្រាប់ព្រះនាង عليها السلام ថា ក្រោយពីស្វ៉ឡាត់រួច ព្រះនាង عليها السلام គប្បីសូត្រដូចតទៅ គឺ៖

اَللّٰهُ اَكْبَرُ (អល់ឡោះហ្វ៍ធំធ្លើងបំផុត) ៣៤ ដង ។

اَلْحَمْدُ لِلّٰهِ (សូមថ្វាយសេចក្តីស្ញើចសរសើរចំពោះអល់ឡោះហ្វ៍) ៣៣ ដង ។

سُبْحَانَ اللّٰهِ (សូមថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ្វ៍) ៣៣ ដង ។

ស្វ៉ឡាត់ប្រៀបបាននឹងផ្កាស្អាតមួយទង តាស់ប៊ិះហ្ហ៍របស់ប៊ីប៊ីហ្វាទី៍ម៉ាស់ អាស់-ស្ហាស់រ៉អ៊ុ عليها السلام ធ្វើឲ្យផ្កានេះមានក្លិនក្រអូប ។

ដូច្នេះ ក្រោយពីស្វ៉ឡាត់រួច យើងគប្បីសូត្រតាស់ប៊ិះហ្ហ៍របស់ប៊ីប៊ីហ្វាទី៍ម៉ាស់ عليها السلام ព្រោះយើងចង់ឲ្យស្វ៉ឡាត់យើងដូចផ្កាដែលក្រអូប ។

## កិច្ចការសិស្ស ១៩

ចូរផាត់ព័ណ៌លើគ្រាប់តាស់ប៊ិះហ៊្វ័ដោយសូត្រះ
៣៤ ដង អល់ឡ៍ហ្វ៊ូ អាក់ុបារ ។
៣៣ ដង អាល់ហ្ាំឌូលិលឡាស្ហ៍ ។
៣៣ ដង ស៊ុបហ្ាណល់ឡោះហ្វ៍ ។

